# គុណសម្បត្តិទាំង ៨ ជួយឲ្យអ្នក បំពេញការងារបានល្អ






- http://PDFKhmer.wordpress.com
- E-mail: PDFKhmer@gmail.com

# គុណសម្បត្តិទាំង ៨ ក្នុងការបំពេញការងារ

នៅក្នុងសង្គមដែលពោរពេញទៅដោយការប្រកួតប្រជែងគ្រប់បែបយ៉ាង សព្វថ្ងៃនេះមនុស្សម្នាក់ៗតែងតែស្វះស្វែងរកការងារថ្មី ដែលខ្លួនពេញចិត្ត ប៉ុន្តែ ពុំមែនចេះតែរក បានងាយៗនោះទេ។ ដូច្នេះ ដើម្បីឲមាន លោកអ្នកឆាប់រកការងារបានធ្វើក្នុងពេលឆាប់ៗ ហើយជាការងារល្អៗនោះ អ្នកគួរមានគុណសម្បត្តិ ទាំង ៩ ចំណុចដូចខាងក្រោម៖



# គុណសម្បត្តិទាំង ៨ ក្នុងការបំពេញការងារ



**១. សមត្ថភាពក្នុងការងារ :**

មុននឹងគេសម្រេចចិត្ត អញ្ជើញអ្នកដាក់ពាក្យមកសម្ភាសន៍ ពួកគេត្រូវប្រាកដក្នុងចិត្តជាមុនសិនស្ដីអំពីលក្ខខណ្ឌមួយចំនួន ។ ដូច្នេះ អ្នកត្រូវផ្ដល់នូវព័ត៌មានលម្អិតអំពី សមត្ថភាពក្នុងការងាររបស់អ្នក តាមរយៈប្រវត្តិរូបសង្ខេប (CV) ឱ្យបានច្បាស់លាស់។

# គុណសម្បត្តិទាំង ៨ ក្នុងការបំពេញការងារ

## ២. ធ្វើការងាររហ័សរហួន:

បើអ្នកមិនមែន ជាបុគ្គលិកថ្នាក់ទាប ចៅហ្វាយភាគច្រើន សម្លឹងរកមនុស្ស ដែលអាច “ ធ្វើការបានឆាប់រហ័ស” ។ ដូច្នេះ បញ្ជាក់ឲគេឃើញថា អ្នកយល់ដឹងពីបែបបទធ្វើការបានយ៉ាងរហ័ស និងមានទំនាក់ទំនងការងារបានយ៉ាងទាន់ចិត្ត។



# គុណសម្បត្តិទាំង ៨ ក្នុងការបំពេញការងារ



## ៣. ភាពជឿជាក់:

ថៅហ្វាយនាយរមែងប្រាកដក្នុងចិត្តថា អ្នកអាចធ្វើការងារបានល្អ ដែលទំនុកចិត្តនេះ អាចបង្កើតឡើងបានតាមរយៈ ការមើលឃើញពីភាពជឿជាក់របស់អ្នក ដែលអាចបញ្ចេញបានច្រើនវិធី ដូចជា៖ ពាក្យសម្ដី យ៉ាងមុតមាំ ដើម្បីបញ្ជាក់ឲឃើញពីបុគ្គលិកលក្ខណៈយកចិត្តទុកដាក់ក្នុងការងារ។

# គុណសម្បត្តិទាំង ៨ ក្នុងការបំពេញការងារ

៤. ការពេញចិត្តៈ

ក្រុមហ៊ុនរមែង សម្លឹងរកមនុស្សដែល ត្រៀមខ្លួននឹងបោះជំហានទៅមុខ ក្នុងក្របខ័ណ្ឌមុខនាទីការងារដែលកំណត់ទុក ដែលបញ្ជាក់ឲឃើញថា អ្នករីករាយ នឹងធ្វើការងារខ្លាំងឡើងៗ ដើម្បីស្វែងរក ភាពជោគជ័យ។



# គុណសម្បត្តិទាំង ៨ ក្នុងការបំពេញការងារ

## ៥. ភាពចុះសម្រុង:

ក្រុមហ៊ុនរមែង រមែងស្វែងរកមនុស្សដែលមានបុគ្គលិកលក្ខណៈ និងការប្រព្រឹត្តិដែល មានភាពចុះសម្រុងនឹងតម្រូវការក្នុងមុខតំណែងការងារ របស់អង្គភាពបាន។ហើយត្រូវចេះសម្របខ្លួនជាមួយមនុស្សដ៏ទៃទៀត ដែលបំរើការងារជាមួយគ្នាផងដែរ។



# គុណសម្បត្តិទាំង ៨ ក្នុងការបំពេញការងារ



៦. គំនិតយោបល់:

ចូរធ្វើការបង្ហាញនូវគំនិតយោបល់របស់លោកអ្នកទៅលើប្រធានបទ ឬបញ្ហាណាដែលពាក់ព័ន្ធនិងការងារជាក្រុមរបស់លោកអ្នក ។គួរតែជៀសវាងការនិយាយអ្វីដែលពិបាកក្នុងការយល់ ឬក្រៅសាច់រឿង ។

# គុណសម្បត្តិទាំង ៨ ក្នុងការបំពេញការងារ

## ៧. ចំណេះដឹងផ្នែកទំនាក់ទំនង:

ការទំនាក់ទំនងបានល្អ គឺត្រូវមានចំណេះដឹង ក្នុងការនិយាយ និងសរសេរឲ្យខ្លាំងពូកែ ហើយការចេះប្រើវិធីសាស្ត្រក្នុងការនិយាយស្ដីបានយ៉ាងសមរម្យ បង្ហាញឲចៅហ្វាយនាយអ្នកយល់ឃើញថា អ្នកមានចំណេះដឹងក្នុងការទំនាក់ទំនង និងចេះប្រើវាបានយ៉ាងល្អ។



# គុណសម្បត្តិទាំង ៨ ក្នុងការបំពេញការងារ

## ៨. ភាពជាអ្នកដឹកនាំ:

ភាពជាអ្នកដឹកនាំ មិនមែនគ្រាន់តែជាគុណសម្បត្តិរបស់អ្នកជំនួញប៉ុណ្ណោះទេ តែបុគ្គលិកផ្នែកផ្សេងៗទៀត ក៏អាចបង្ហាញភាពជាអ្នកដឹកនាំ បានដោយរកវិធីធ្វើការងាររបស់ខ្លួនឯង ឲ្យប្រសើរឡើង ឬធ្វើជាគំរូដល់អ្នក រួមការងារ ដើម្បីបញ្ជាក់ឲ្យចៅហ្វាយនាយឃើញថា អ្នកក្លាហាននឹងធ្វើជា អ្នកដឹងនាំមិនថានៅក្នុងកំរិតណា ឬតួនាទីណាក៏ដោយ។



# សូមអរគុណ